# ផ្ទៃរឿង អ័ដាមនិងអ័ដាមក្រោយបង្អស់

**មេរៀនទី៦ អ័ដាមនិងអ័ដាមក្រោយបង្អស់ លោកុប្បត្តិ ២-៣**

នៅពេលយើងគិតអំពីរបៀបនៃការប្រកាសដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទពីលោកុប្បត្តិ ២-៣ វិធីដែលយើងអាចមើលឃើញនោះគឺតាមរយៈលោកអ័ដាម។ ជាថ្មីម្តងទៀត នៅពេលអ្នកសរសេរគម្ពីរសញ្ញាថ្មី បង្រៀនអំពីលោកអ័ដាមពួកគេបានប្រើប្រាស់សាច់រឿងអំពីលោកអ័ដាម ដើម្បីជួយពន្យល់អំពីព្រះយេស៊ូវគ្រីស្ទ។ អត្ថបទពីរដ៏សំខាន់អំពីរឿងនេះគឺមាននៅក្នុងគម្ពីររ៉ូម ៥:១២-២១ និង ១កូរិនថូស១៥:២០-២២, ៣៥-៤។

## រ៉ូម ៥:១២-២១

នៅក្នុងគម្ពីររ៉ូម លោកប៉ូល ពន្យល់អំពីរបៀបដែល ព្រះជាម្ចាស់បានរាប់យើងទុកជាសុចរិតនិងប្រទានជីវិត និងសេចក្តីសង្គ្រោះដល់មនុស្សជាច្រើនដោយសារតែម្នាក់ គឺព្រះយេស៊ូវគ្រីស្ទ។ ដើម្បីបង្ហាញនូវគោលការណ៍នេះ សាវ័កប៉ូល បានធ្វើការប្រៀបធៀប និងបង្ហាញភាពផ្ទុយគ្នារវាងព្រះគ្រីស្ទ និងលោកអ័ដាម ព្រមទាំងរៀបរាប់អំពីក្រុមមនុស្សពីរក្រុម គឺមួយក្រុមក្នុងអ័ដាមនិងមួយក្រុមក្នុងព្រះគ្រីស្ទ។

នៅក្នុងខ ១២ សាវ័កប៉ូលបញ្ជាក់ថា ទង្វើមិនស្តាប់បង្គាប់ របស់លោកអ័ដាមនាំឲ្យមានអំពើបាប និង សេចក្តីស្លាប់ ដល់ពិភពលោកទាំងមូល។ គ្រប់គ្នាត្រូវស្លាប់ដោយព្រោះការប្រព្រឹត្តិអំពើរំលងរបស់មនុស្សតែម្នាក់ (គឺលោកអ័ដាម)(ខ១៥) ហើយអំណោយទាន នៃព្រះគុណកើតមានមក ដល់មនុស្ស ជាច្រើន ដោយសារមនុស្សតែម្នាក់ គឺព្រះយេស៊ូវ។ ប៉ុន្តែ នៅ ក្នុងខ១៥ដល់១៧ សាវ័កប៉ូលនិយាយថា លោកអ័ដាមនិងព្រះគ្រីស្ទយេស៊ូវ **មិនដូចគ្នានោះទេ** ដោយ ព្រោះសេចក្តីស្លាប់កើតមានដោយសារ អំពើរំលងមួយ ប៉ុន្តែអំណោយទានតាមរយៈព្រះគ្រីស្ទមកបន្ទាប់ពីអំពើរំលងជាច្រើន។ ហេតុដូច្នេះ សាវ័កប៉ូល បញ្ជាក់ពី សេចក្តីសប្បុរសនៃព្រះគុណរបស់ព្រះជាម្ចាស់។

បន្ទាប់មក នៅក្នុងខ១៨ ដល់១៩ សាវ័កប៉ូល បញ្ជាក់ជាថ្មីម្តងទៀត អំពីរបៀបដែលលោកអ័ដាមនិងព្រះគ្រីស្ទ **ដូចគ្នា។** ដោយអំពើរំលងតែមួយរបស់ លោក អ័ដាមនាំឲ្យមានការថ្កោលទោសដល់មនុស្សទាំងអស់ នោះមនុស្សទាំងអស់ក៏បានរាប់ជាសុចរិត ឱ្យបានជីវិតវិញ ដោយសារអំពើសុចរិតតែ ១របស់ព្រះគ្រីស្ទ *បែបដូច្នោះ ដែរ។*

## ១កូរិថូស១៥

នៅក្នុងជំពូកនេះ សាវ័កប៉ូលបង្រៀនអំពីការរស់ឡើងវិញពីសេចក្តីស្លាប់នៃអង្គព្រះយេស៊ូវ ហើយលទ្ធផលនៃការរស់ឡើងវិញពីសេចក្តីស្លាប់នោះ ដែលជាការរស់ ឡើងវិញពីសេចក្តីស្លាប់ដល់អស់អ្នកដែលជឿលើព្រះយេស៊ូវ។ នៅក្នុងខ២០ លោកប៉ូល សរសេរថាការរស់ឡើងវិញពីសេចក្តីស្លាប់នៃអង្គព្រះយេស៊ូវ គឺជាផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ។ ផលដំបូងគឺជាភស្តុតាងសម្រាប់ការច្រូតកាត់នាំពេលអនាគត ហេតុដូច្នេះ ការរស់ឡើងវិញពីសេចក្តីស្លាប់នៃ អង្គព្រះយេស៊ូវ គឺជាភស្តុតាងថាអស់អ្នកដែលជាប់នៅក្នុងទ្រង់ (គឺជឿលើទ្រង់) និងរស់ឡើយវិញផងដែរ។

ដើម្បីបញ្ជាក់ចំនុចនេះ ជាថ្មីម្តងទៀត សាវ័កប៉ុល ធ្វើការ ប្រៀបធៀបព្រះគ្រីស្ទទៅនឹងលោកអ័ដាម។ ក្នុងការធ្វើ បែបនេះ សាវ័កប៉ុល នឹងធ្វើការពិពណ៌នាមនុស្សពីរក្រុម គឺអស់អ្នកដែលនៅជាប់ក្នុងអ័ដាមនិងអស់អ្នកដែល នៅជាប់ក្នុងព្រះគ្រីស្ទ។ នៅក្នុងអ័ដាមគ្រប់គ្នាត្រូវស្លាប់ ប៉ុន្តែនៅក្នុងព្រះគ្រីស្ទ ទាំងអស់គ្នានឹងទទួលបានជីវិត (ខ២២)។ ពាក្យថា *ទាំងអស់គ្នាដែលនឹងទទួលបានជីវិត* នៅក្នុងព្រះគ្រីស្ទ មិនមែនមានន័យថា មនុស្សម្នាក់ៗទាំងអស់ នោះទេ ពីព្រោះនៅខបន្ទាប់សាវ័កប៉ុលពន្យល់យ៉ាងច្បាស់ថា គឺគាត់សំដៅទៅអស់អ្នកណាដែលនៅជាប់នឹងព្រះគ្រីស្ទ នោះនឹងបានជីវិត។

នៅក្នុងគម្ពីរ ១កូរិនថូស ១៥:៤៤-៤៩ សាវ័កប៉ុល សរសេរពីភាពផ្ទុយគ្នារវាងលោកអ័ដាម និងព្រះយេស៊ូវ គ្រីស្ទ។ លោកអ័ដាមជាមនុស្សមានព្រលឹងរស់ ប៉ុន្តែព្រះគ្រីស្ទ ដែលត្រូវបានហៅថាជា អ័ដាមក្រោយបង្អស់ គឺវិញ្ញាណដ៏ប្រោសឲ្យរស់វិញ (ខ៤៥) ។ នៅក្នុងខ៤៧ លោកអ័ដាម ត្រូវបានហៅថាជា មនុស្សមុនដំបូង ដែលកើតមកពីធូលីដី ប៉ុន្តែព្រះគ្រីស្ទ នៅទីនេះ ត្រូវបានហៅថាជាមនុស្សទីពីរចេញមកពីស្ថានសួគ៌។ អស់អ្នកដែលនៅជាប់ក្នុងលោកអ័ដាម គឺជាមនុស្សដែលកើតពីធូលីដីផងដែរ។ ហើយអស់អ្នកដែលនៅជាប់ក្នុង

ព្រះគ្រីស្ទគឺជាពួកស្ថានសួគ៌ដែរ (ខ៤៨)។ អស់ អ្នកដែលកើតមកមានរូបរាងដូចអ័ដាម តែគ្រីស្ទបរិស័ទមានរូបរាងដូចជា មនុស្សមកពីស្ថានសួគ៌ គឺជាព្រះគ្រីស្ទ (ខ៤៩)។

ដូចនេះ រឿងអំពីលោកអ័ដាម នៅក្នុងលោកុប្បត្តិ ជំពូក២-៣មិនមែនគ្រាន់តែជារឿងអំពីអំពើបាបរបស់មនុស្សម្នាក់នោះទេ តែគឺជារឿងដែលមានលទ្ធផលយ៉ាងធំសម្បើម សម្រាប់មនុស្សទាំងអស់។ ផ្ទៃរឿងនៃ ការបះបោររបស់លោកអ័ដាមមានសារៈសំខាន់ក្នុងការពន្យល់អំពីបញ្ហារបស់មនុស្សនាពេលបច្ចុប្បន្ន។ ហេតុដូច្នេះ ទោះបីជាយើងអាចមើលឃើញនៅក្នុងរឿងអំពីលោកអ័ដាម ថាជាការព្រមានដល់យើងគ្រប់គ្នាត្រូវតែគោរពស្ដាប់បង្គាប់ព្រះជាម្ចាស់យ៉ាងណាក៏ដោយ បើយើងកាត់ស្រាយរឿងនេះថាជាគោលការណ៍សីលធម៌ នោះយើងមិនទាន់បានយល់យ៉ាងពេញលេញអំពីរឿងនេះ។

បញ្ហារបស់មនុស្សនានា រួមទាំងលោកអ្នក ហើយនឹងខ្ញុំ និងមិត្តភ័ក្តិញាតិសណ្ដានទាំងអស់ គឺថា យើងទាំងអស់ គ្នាគឺជាកូនចៅរបស់លោកអ័ដាម ហើយយើងចូលរួមចំនែកក្នុងការទទួលយកនូវលទ្ធផល ដែលជាការកាត់ទោស និងសេចក្ដីស្លាប់។ នេះគឺជាបញ្ហាដ៏ធំបំផុតរបស់មនុស្ស។ បញ្ហាដ៏ធំបំផុតរបស់យើងមិនមែនអំពីប្រាក់ ឬបញ្ហាសុខភាព ប៉ុន្តែយើងស្ថិតក្រោមការកាត់ទោសរបស់ព្រះជាម្ចាស់។ យើងមិនអាចជៀសផុតពីទោសនេះ ដោយព្យាយាមស្ដាប់បង្គាប់ព្រះជាម្ចាស់។

សេចក្ដីសង្ឃឹមតែមួយគត់របស់យើងគឺ ព្រះជាម្ចាស់នឹងរាប់យើងជាសុចរិតនិងប្រទានជីវិតតាមរយៈដំណឹងល្អនៃព្រះគ្រីស្ទយេស៊ូវ។ ហេតុដូច្នេះ ជាថ្មីម្ដងទៀត ការអនុវត្តជាក់ស្ដែងនូវរឿងរបស់លោកអ័ដាម នៅក្នុងលោកុប្បត្តិ ជំពូក ២ ដល់ ៣ គឺត្រូវទុកចិត្តព្រះយេស៊ូវ ជឿដំណឹងល្អរបស់ព្រះយេស៊ូវ ដែលយើងបានរាប់ជាសុចរិតតាមរយៈសេចក្ដីសុគតរបស់ទ្រង់ និងការរស់ឡើងវិញពីសុគត។ ដូច្នេះ ជាថ្មីម្ដងទៀត សម្រាប់គ្រូបង្រៀន និងគ្រូប្រកាសដំណឹងល្អ នៅពេលយើងបង្រៀនអំពីរឿងរបស់លោកអ័ដាម យើងគួរតែ បង្ហាញនូវការអនុវត្តជាក់ស្ដែង ដែលអ្នកស្ដាប់ គួរតែជឿលើព្រះយេស៊ូវ និងដាក់សេចក្ដីទុកចិត្តក្នុងទ្រង់ដោយអំណរ។ នេះគឺជា របៀបដែលអ្នកសរសេរគម្ពីរសញ្ញាណថ្មីអនុវត្តរឿង របស់លោកអ័ដាម។

